# ព្រះរាជក្រឹត្យ

នស / រកត /០២០៤/០៣០

យើង

ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់អោយប្រើជាផ្លូវការនូវច្បាប់រដ្ឋធម្មនុញ្ញ ស្ដីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និង មាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅ ថ្ងៃទី០៤ ខែមីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត្យ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៩ ស្ដីពីការតែងតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់ព្រះរាជក្រឹត្យ នស/រកត/០៣៩៩/៤៤ ចុះថ្ងៃទី១១ ខែ មីនា ឆ្នាំ១៩៩៩. ព្រះរាជក្រឹត្យ នស/រកត/០៣៩៩/៦៨ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ ១៩៩៩ និងព្រះរាជក្រឹត្យ នស/រកត/ ០៣៩៩/៧០ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៩ ស្ដីពីការតែងតាំងសមាជិក សមាជិកាព្រឹទ្ធសភា
- បានទ្រង់យល់ព្រះរាជសារ ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៤ ដែលប្រោសព្រះរាជទានសេចក្ដីអនុញ្ញាតឱ្យបន្តនីតិកាលទី១ របស់ព្រឹទ្ធសភាមួយឆ្នាំ
- បានទ្រង់យល់សេចក្ដីអនុម័តស្ដីពីការបន្តនីតិកាលទី១ នៃព្រឹទ្ធសភា នាសម័យប្រជុំសាមញ្ញលើកទី៩ របស់ព្រឹទ្ធសភានីតិកាលទី១ នាថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៤
- តាមសេចក្ដីក្រាបបង្គំទូលស្នើរបស់ប្រធានព្រឹទ្ធសភាស្ដីទី តាមលិខិតលេខ ០១២/០២០៤/ព.ស ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៤

## ត្រាស់បង្គាប់

**មាត្រា១:** ប្រកាសបន្តនីតិកាលទី១ នៃព្រឹទ្ធសភា ដែលត្រូវផុតកំណត់នាថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០០៤ ក្នុងរយៈពេលមួយឆ្នាំទៅមុខទៀត ។

**មាត្រា២:** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ.ថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ ២០០៤

គ្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្ដីទី

លេខ: ២២ ច ល ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

៣៤៨. ០៤.០២.០៣០ ដើម្បីចម្លងចែក

រាជធានីភ្នំពេញ.ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

សាន់ តាន់